00755096

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

E141/1

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 24 / 11 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé: Ratanak

**សាធារណៈ / Public**

**អង្គជំនុំជម្រះសាលាដំបូង**

កាលបរិច្ឆេទ: ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ជូនចំពោះ:** Wendy LOBWEIN, **ប្រធានអង្គភាពគាំពារសាក្សី និងអ្នកជំនាញ**

**ពី:** Susan LAMB, **មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងភាគីទាំងអស់នៃសំណុំរឿង ០០២**

**កម្មវត្ថុ:** **ការប្រគល់ចម្លើយមុនៗឲ្យសាក្សីមុនពេលសាក្សីធ្វើសក្ខីកម្មនៅសវនាការ**

ដូចដែលបានបញ្ជាក់នៅក្នុងអនុស្សរណៈមួយចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ឯកសារ E141) ផ្ញើជូនភាគី អង្គជំនុំជម្រះបានបញ្ជាក់នាពេលថ្មីៗនេះថា កិច្ចដំណើរការនីតិវិធីជំនុំជម្រះអាចកាន់តែមានប្រសិទ្ធភាពមួយកម្រិតទៀត ប្រសិនបើសាក្សីមានឱកាសរំឭកការចងចាំរបស់ពួកគាត់តាមរយៈការពិនិត្យមើលចម្លើយមុនៗរបស់ពួកគាត់ឡើងវិញ នៅមុនពេលពួកគាត់ផ្តល់សក្ខីកម្ម។ អង្គជំនុំជម្រះនឹងប្រគល់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញនូវចម្លើយមុនៗរបស់សាក្សីម្នាក់ៗ ដើម្បីសាក្សីអាចពិនិត្យមើលចម្លើយរបស់ខ្លួនឡើងវិញមុនពេលផ្តល់សក្ខីកម្មនៅសវនាការ។ អនុស្សរណៈនេះមានគោលបំណងផ្តល់ការណែនាំពាក់ព័ន្ធនឹងវិសាលភាព និងគោលបំណងនៃភារកិច្ចនេះ ក៏ដូចជាដើម្បីធានាតម្លាភាពចំពោះភាគីឲ្យបានជាអតិបរមា។

គំនិតផ្តួចផ្តើមខាងលើគឺសំដៅបញ្ចៀសការខ្ជះខ្ជាយពេលវេលាដ៏មានតម្លៃរបស់សវនាការ ប្រសិនបើសាក្សីត្រូវការរំឭកចម្លើយចាស់ៗរបស់ខ្លួន ឬបញ្ជាក់ថាចម្លើយទាំងនោះពិតជាចម្លើយរបស់ខ្លួនប្រាកដមែន (ដូចជាតាមរយៈការផ្ទៀងផ្ទាត់ហត្ថលេខា ឬស្នាមមេដៃ) នៅមុនពេលឆ្លើយសំណួរនៅសវនាការ។ អង្គជំនុំជម្រះយល់ថា សាក្សីគួរត្រូវបានផ្តល់ឱ្យនូវចម្លើយកាលពីពេលមុនៗ ហើយអង្គភាពគាំពារសាក្សី និងអ្នកជំនាញគួរណែនាំសាក្សីទាំងនោះឱ្យស្គាល់ពីដំណើរការប្រព្រឹត្តទៅនៅក្នុងសាលសវនាការ អ.វ.ត.ក ជាមុនផងដែរ។

អង្គជំនុំជម្រះនឹងប្រគល់ឯកសារចម្លើយមុនៗពាក់ព័ន្ធទៅឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ មុនពេលសាក្សីមកដល់ អ.វ.ត.ក។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញត្រូវប្រគល់ឯកសារចម្លើយមុនៗរបស់សាក្សីទៅឱ្យសាក្សី និងទុកពេលវេលាឱ្យសាក្សីអានចម្លើយទាំងនោះ។ នៅពេលសាក្សីអានចប់ អង្គភាពគាំពារសាក្សី និងអ្នកជំនាញគួរយកចម្លើយនោះទៅកម្ទេចដើម្បីជៀសវាងការបែកធ្លាយព័ត៌មានសម្ងាត់ដោយអចេតនា ឬការចោទប្រកាន់ថាសាក្សីឃុបឃិតគ្នា។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញពុំគួរគប្បីឆ្លើយសំណួរណាមួយដែល

សាក្សីសួរពាក់ព័ន្ធនឹងខ្លឹមសារនៃចម្លើយ ឬព្យាយាមផ្តល់យោបល់ណាមួយពាក់ព័ន្ធនឹងចម្លើយសាក្សីឡើយ។ ប្រសិនបើសាក្សីជាអនក្ខរជន ឬពុំមានលទ្ធភាពអានចម្លើយបាន អង្គភាពគាំពារសាក្សី និងអ្នកជំនាញអាចអានចម្លើយនេះឱ្យសាក្សីស្តាប់ដោយពុំមានការបន្ថែមបន្ថយយោបល់ផ្ទាល់ខ្លួន។

ក្នុងករណីសាក្សី ឬអង្គភាពគាំពារសាក្សី និងអ្នកជំនាញជួបប្រទះបញ្ហាណាមួយក្នុងអំឡុងពេលអនុវត្តភារកិច្ចខាងលើ សូមជូនដំណឹងមកនាងខ្ញុំដើម្បីនាងខ្ញុំជូនដំណឹងបន្តឱ្យអង្គជំនុំជម្រះ និងភាគីបានដឹងតាមការសមស្រប។

អង្គជំនុំជម្រះពឹងផ្អែកលើសហមេធាវីនាំមុខក្នុងការធានាថាដើមបណ្តឹងរដ្ឋប្បវេណីកំហិតព័ត៌មាន ដែលខ្លួនប្រគល់ជូនអង្គជំនុំជម្រះត្រឹមព័ត៌មានពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ និងត្រៀមខ្លួនរួចរាល់សម្រាប់សវនាការ ដើម្បីឱ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅបានឆាប់រហ័ស។ ហេតុដូច្នេះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញពុំមានតួនាទីផ្ទាល់ពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬចម្លើយមុនៗរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

បន្ទាប់ពីអង្គជំនុំជម្រះបានបង្គាប់ឱ្យបំបែកសំណុំរឿង អ្នកជំនាញមួយចំនួនអាចទទួលបានការណែនាំអំពីការកំណត់វិសាលភាពនៃសក្ខីកម្មរបស់អ្នកជំនាញ តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញតាមការចាំបាច់នៃសំណុំរឿង ០០២/០១។